00610927

F511

# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០១/១៨-០៧-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

សាធារណៈ:

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 29 / 09 / 2010
ម៉ោង (Time/Heure): 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

---

## សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រ ដើម្បីដាក់សេចក្ដីសន្និដ្ឋានបណ្ដឹងសាទុក្ខរបស់ខ្លួន

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY
លោក យ៉េត ចរិយា
លោក William SMITH
លោក ច័ន្ទ តារាវុស្សី
លោក Anees AHMED

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រឹម, ប្រធាន
ចៅក្រម Motoo NOGUCHI
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រម C. N. JAYASINGHE
ចៅក្រម យ៉ា ណារិន

**ជនជាប់ចោទ/ចុងបណ្ដឹងសាទុក្ខ:**

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី:**
លោក គង់ ពិសី
លោក ហុង គីមសួន
លោក យុង ផានិត
លោក គីម ម៉េងឃី
កញ្ញា ម៉ុច សុវណ្ណារី
កញ្ញា SILKE Studzinsky
លោកស្រី Martine JACQUIN
លោក Philippe CANONNE
លោកស្រី ទី ស្រីនណា
លោក Pierre-Olivier SUR
លោក Alain WERNER

F511

*សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក*

| | |
|---|---|
| កាំង ហ្គេកអ៊ាវ *ហៅ* ឌុច: | លោក Brianne McGONIGLE |
| | លោកស្រី Annie DELAHAIE |
| **មេធាវីជនជាប់ចោទ/ចុងបណ្ដឹងសាទុក្ខ:** | លោកស្រី Elizabeth RABESANDRATANA |
| លោក ការ សាវុត្ថ | លោក Karim KHAN |
| លោក កង ឫទ្ធារី | លោកស្រី Fabienne TRUSSES-NAPROUS |

00610929

F511

*សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក*

# សេចក្ដីសន្និដ្ឋាន

១. នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១០ សហព្រះរាជអាជ្ញា បានដាក់ពាក្យសុំមួយច្បាប់ដែលស្នើសុំអង្គជំនុំជម្រះតុលាការកំពូល បន្ថែមចំនួនទំព័រកំណត់សម្រាប់ដាក់សេចក្ដីសន្និដ្ឋានបណ្ដឹងសាទុក្ខរបស់ខ្លួនពី៣០ទំព័រ ដល់៤៥ទំព័រ នៅក្នុងការដាក់ឯកសារជាភាសាអង់គ្លេស ("សំណើលើកទីមួយ")[1] ។ សហព្រះរាជអាជ្ញាអះអាងថា ការបន្ថែមទំព័រកំណត់នេះ ត្រូវបានអនុញ្ញាតដោយហេតុថា (១) បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមខុសប្លែកពីបណ្ដឹងឧទ្ធរណ៍ធម្មតា និងតម្រូវឱ្យមានចំនួនទំព័រកំណត់ច្រើនជាង និងដោយសារ (២) សេចក្ដីសន្និដ្ឋានបណ្ដឹងសាទុក្ខដែលស្នើឡើងនេះ នឹងលើកអំពីទឡ្ហីករណ៍បីសំខាន់ និងអនុទឡ្ហីករណ៍មួយចំនួនទៀត ។ ភាគីចុងបណ្ដឹងសាទុក្ខ កាំង ហ្គេកអ៊ាវ ហៅ ឌុច មិនបានឆ្លើយតបទៅនឹងពាក្យសុំលើកទីមួយទេ ហើយអង្គជំនុំជម្រះតុលាការកំពូលក៏មិនទាន់បានសម្រេចលើពាក្យសុំនេះនៅឡើយដែរ។

២. ឥឡូវនេះ សហព្រះរាជអាជ្ញា បានបំពេញរួចរាល់ហើយនូវសារណាលើបណ្ដឹងសាទុក្ខដោយពិនិត្យមើលម៉ត់ចត់លើការរកឃើញនានាផ្នែកអង្គហេតុ និងអង្គច្បាប់ដែលនៅក្នុងសាលក្រម ដើម្បីគាំទ្រដល់បណ្ដឹងសាទុក្ខរបស់ខ្លួន ។ ក៏ប៉ុន្តែ ពង្រាងចុងក្រោយជាភាសាអង់គ្លេស រួមទាំងទំព័រមុខ មាតិការឿង និងសេចក្ដីសន្និដ្ឋានទាក់ទងនឹងនីតិវិធី និងសេចក្ដីសន្និដ្ឋានដ៏មានសារៈសំខាន់ផង បានឡើងរហូតទៅដល់៦៥ទំព័រ។ បន្ទាប់ពីការវាយតម្លៃជាលម្អិតមួយទៅលើសេចក្ដីសន្និដ្ឋានលើបណ្ដឹងសាទុក្ខ សហព្រះរាជអាជ្ញាបានធ្វើសេចក្ដីសន្និដ្ឋានថា ការកាត់បន្ថយណាមួយចេញពីចំនួនទំព័រខាងលើនេះ គឺមុខជានឹងធ្វើឱ្យខូចដល់បូរណភាពនៃសេចក្ដីសំអាងរបស់ខ្លួន ហើយនឹងមិនបំរើឱ្យផលប្រយោជន៍នៃយុត្តិធម៌នោះឡើយ ។ ហេតុដូចនេះ សហព្រះរាជអាជ្ញា សូមស្នើដល់អង្គជំនុំជម្រះតុលាការកំពូល សុំបន្ថែមចំនួនទំព័រពីលើចំនួនកំណត់រហូតដល់អតិបរមា៦៥ទំព័រជាភាសាអង់គ្លេស។ មូលហេតុនៃការបន្ថែមចំនួនទំព័រខាងលើនេះ ជាសំខាន់គឺវាដូចគ្នានឹងមូលហេតុដែលបានលើកឡើងនៅក្នុងពាក្យសុំលើកទីមួយដែរ ហើយហេតុនេះ ត្រូវបានរួមបញ្ចូលនៅក្នុងនេះដោយការលើកជាសេចក្ដីយោង *ដោយមានការកែប្រែប្រសិនបើមានការចាំបាច់* ។

៣. បើសិនជា ត្រូវបានអនុញ្ញាតឱ្យនោះ ការបន្ថែមចំនួនទំព័ររហូតដល់៦៥ទំព័រនេះ នឹងមិនធ្វើឱ្យខូចខាតដល់សិទ្ធិរបស់ចុងបណ្ដឹងសាទុក្ខឡើយ ហើយសហព្រះរាជអាជ្ញា នឹងមិនមានការជំទាស់ទេចំពោះការសុំបន្ថែមចំនួនទំព័រ ពីលើចំនួនកំណត់ណាមួយដែលប្រហាក់ប្រហែលគ្នានេះ ដែលចុងបណ្ដឹងសាទុក្ខអាចនឹងស្នើសុំ ដើម្បីដាក់សារណាឆ្លើយតបរបស់ខ្លួនឡើយ ។ សហព្រះរាជអាជ្ញាយល់ឃើញថា បញ្ញត្តិទាំងឡាយដែលចែងទាក់ទងនឹងនីតិវិធី ទោះបីជាមានសារៈសំខាន់ស្មើគ្នាក៏ដោយ ក៏មិនត្រូវដាក់កម្រិតទៅលើសមត្ថភាពរបស់ភាគីណាមួយ ដើម្បីឱ្យធ្វើសារណាឱ្យបានពេញលេញជូនទៅអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងបញ្ហាដ៏មានសារៈសំខាន់ តួយ៉ាងដូចជាបញ្ហា

---

[1] សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រសម្រាប់សេចក្ដីសន្និដ្ឋានបណ្ដឹងសាទុក្ខរបស់ខ្លួន, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក, ដែលបានដាក់កាលពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១០ និងបានជូនដំណឹងដល់គូភាគីនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១០ ("សំណើលើកទីមួយ") ។

ទាំងនេះដែរ។ ក្នុងស្មារតីដូចគ្នានេះដែរ សហព្រះរាជអាជ្ញា មិនបានជំទាស់ចំពោះសំណើរបស់ចុងបណ្តឹងសាទុក្ខដែលស្នើសុំពន្យារពេលបន្ថែមចំនួនមួយខែទៀត ដើម្បីដាក់បណ្តឹងសាទុក្ខតបវិញនោះទេ[2] ។

៤. សហព្រះរាជអាជ្ញា បានប្រឹក្សាយោបល់ជាមុនរួចហើយជាមួយនឹងអ្នកដឹកនាំក្រុមមេធាវីការពារក្តីជាតិគឺ លោក ការ សាវុត្ថ ។ លោក សាវុត្ថ បានបញ្ជាក់ថា លោកពុំមានការជំទាស់ទៅនឹងការសុំបន្ថែមចំនួនទំព័រដែលបានស្វែងរកពីសំណាក់សហព្រះរាជអាជ្ញាទេ[3]។

## សំណើ

៥. សហព្រះរាជអាជ្ញា សូមស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូល អនុញ្ញាតលើសំណើសុំលើកទីពីរនេះ និងអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាធ្វើការដាក់សេចក្តីសន្និដ្ឋានបណ្តឹងសាទុក្ខរបស់ខ្លួន មិនលើសពីចំនួនហុកសិបប្រាំ(៦៥)ទំព័រ។

៦. សហព្រះរាជអាជ្ញា សូមបញ្ជាក់ថា សហព្រះរាជអាជ្ញានឹងមិនធ្វើការជំទាស់ទៅនឹងការស្នើសុំបន្ថែមចំនួនទំព័រស្រដៀងគ្នានេះ ដែលបានស្វែងរកពីសំណាក់ចុងបណ្តឹងសាទុក្ខនៅក្នុងការដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសេចក្តីសន្និដ្ឋានបណ្តឹងសាទុក្ខនេះទេ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | |

[2] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងពាក្យសុំរបស់ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ដែលស្នើសុំពន្យារពេលបន្ថែមដើម្បីដាក់សារណាលើបណ្តឹងសាទុក្ខរបស់ខ្លួន, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក-អជតក, ដែលបានដាក់ជូនកាលពីថ្ងៃទី២៨ កញ្ញា ២០១០ និងដែលមិនទាន់បានជូនដំណឹងដល់ភាគីនានានៅឡើយ។

[3] ការប្រាស្រ័យទាក់ទងគ្នាតាមទូរស័ព្ទរវាង សហព្រះរាជអាជ្ញាជាតិ ជាមួយនឹងលោក សាវុត្ថ នៅថ្ងៃទី២៩ កញ្ញា ២០១០ ។